# Guide to Access GEF Small Grants Programme UNDP

# គោលការណ៍ណែនាំដើម្បីទទួលបានជំនួយឥតសំណងខ្នាតតូច

## បេសកកម្មនៃកម្មវិធីជំនួយខ្នាតតូច (GEF SGP Mission)

កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក (GEF SGP) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩២ ដែលជាឆ្នាំនៃកិច្ចប្រជុំកំពូលនៅលើពិភពលោក (Rio Earth Summit)។ កម្មវិធីជំនួយ ខ្នាតតូច GEF SGP បង្កប់នូវខ្លឹមសារសំខាន់នៃការអភិវឌ្ឍប្រកបដោយចីរភាពដោយ "គិតពីគួរពីពិភពលោកតាមរយៈធ្វើសកម្មភាពនៅមូលដ្ឋាន"។ តាមរយៈផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់គម្រោងនានាដែលអភិរក្ស និងស្តារបរិស្ថានឡើងវិញ ទន្ទឹមនឹងការលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្មវិធីជំនួយខ្នាតតូចបានបង្ហាញថាសកម្មភាពនានារបស់សហគមន៍អាចរក្សាបាននូវតុល្យភាពដ៏ល្អរវាង តម្រូវការរបស់មនុស្ស និងមុខងារបរិស្ថាន។

## កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក

កម្មវិធីជំនួយខ្នាតតូច (SGP) នៃមូលនិធិបរិស្ថានពិភពលោក (GEF) អនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) ក្នុងនាមដៃគូភាពជាដៃគូ GEF គឺជាកម្មវិធីសាជីវកម្ម ដែលផ្តល់ជំនួយខ្នាតតូចដល់គំនិតផ្តួចផ្តើមដែលដឹកនាំដោយសហគមន៍ដើម្បីដោះស្រាយបរិស្ថានពិភពលោក និងបញ្ហានិរន្តរភាពនៃការអភិវឌ្ឍន៍។ កម្មវិធីត្រូវបានរចនាឡើងជាពិសេសដើម្បីបង្កើតសកម្មភាពក្នុងស្រុកដោយផ្តល់អំណាចដល់អង្គការសង្គមស៊ីវិល សហគមន៍ក្រីក្រនិងក្រុមជនងាយរងគ្រោះរួមទាំងជនជាតិដើមភាគតិចស្ត្រី និងជនដែលមានពិការភាពផងដែរ។

SGP នៅតែជាផ្នែកមួយនៃគំនិតផ្តួចផ្តើមដ៏ល្អបំផុតរបស់មូលនិធិបរិស្ថានពិភពលោក (GEF)ផ្តល់ការគាំទ្រសហគមន៍ឱ្យអនុវត្តគម្រោងដែលមានប្រសិទ្ធភាព និងមានប្រសិទ្ធិផលក្នុងគោលបំណងដើម្បីសម្រេចបានផលប្រយោជន៍បរិស្ថានពិភពលោក ខណៈពេលលើកកម្ពស់ជីវភាព និងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាលើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (GEF និង UNDP, 2015) ។ កម្មវិធីជំនួយខ្នាតតូចមានយន្តការក្នុងការចាត់ចែង និងគ្រប់គ្រងថ្នាក់ជាតិដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោងជាង ២១.៦០០ នៅក្នុង ១២៥ ប្រទេសដែលមានជំនួយឥតសំណងសរុបចំនួន ៥៤២ លានដុល្លារ។ ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមកបណ្តាប្រទេសដែលចូលរួមនៅក្នុង SGP បានកើនឡើងជាលំដាប់ពីប្រទេស ១១ ក្នុងពេលចាប់ផ្តើម រហូតដល់ចំនួន ១២៥ ប្រទេសនាពេលថ្មីៗនេះ។ ក្នុងបណ្តាប្រទេសទាំង១២៥ដែលអនុវត្ត កម្មវិធី

ជំនួយ ខ្នាតតូចមាន ៦៩ ជាប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) និងរដ្ឋអភិវឌ្ឍន៍កោះតូច (SIDS) ដែលប្រទេសមួយចំនួនកំពុងស្ថិតនៅក្នុងស្ថានភាពក្រោយជម្លោះ ឬស្ថានភាពមានវិបត្តិ។

នៅប្រទេសកម្ពុជាបានចូលរួមក្នុងកម្មវិធីជំនួយខ្នាតតូច GEF ជាសកលនៅឆ្នាំ ២០០៤។ គណៈកម្មការជាតិដឹកនាំកម្មវិធីជំនួយខ្នាតតូច (NSC) បានបង្កើតឡើងក្នុងឆ្នាំ ២០០៥ ដំបូងដើម្បីគ្រប់គ្រងទាំងកម្មវិធីជំនួយខ្នាតតូច GEF SGP UNDP និង កម្មវិធីជំនួយខ្នាតតូចនៃកម្មវិធីលើកកម្ពស់ព្រៃត្រូពិច (SGP PTF) ដែលបានដំណើរការរហូត ដល់ឆ្នាំ ២០០៧។ កម្មវិធីជំនួយខ្នាតតូច GEF SGP UNDP និង SGP-PTF ត្រូវបានបង្កើតឡើង ក្នុងពេលតែមួយនៅប្រទេសកម្ពុជាជាមួយនឹងពិធីបើកសម្ពោធប្រកាសផ្តល់ជំនួយរួមគ្នានៅថ្ងៃទី ៣១ ខែសីហាឆ្នាំ ២០០៥ ។កម្មវិធីទាំងពីរបានប្រើប្រាស់គណៈកម្មការជាតិដឹកនាំតែមួយ និងមាននីតិវិធីស្រដៀងគ្នាជាច្រើន។

នៅចុងឆ្នាំ ២០១០ ប្រទេសកម្ពុជា GEF SGP បានកៀគរថវិកាជាង ៤ លានដុល្លារពីរដ្ឋាភិបាលស៊ុយអ៊ែត/ស៊ីដាជាមួយហិរញ្ញប្បទានស្របគ្នា របស់កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍នៅតំបន់មេគង្គ អាស៊ីប៉ាស៊ីហ្វិក (MAP CBA) ដើម្បីអនុវត្តកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍កម្ពុជា (CCBAP) ដែលមានរយៈពេល ៤ ឆ្នាំអនុវត្តដោយយូអិនឌីភីប្រចាំប្រទេសកម្ពុជា ដោយប្រើយន្តការរបស់ SGP ក្នុងការ ផ្តល់ជំនួយខ្នាតតូច និងការគ្រប់គ្រងកម្មវិធីទាំងមូល និងប្រើ NSC ជាមួយគ្នានិង GEF SGP ដែរ។

ចាប់តាំងពី GEF OP3 ដល់ OP6 ប្រទេសកម្ពុជា SGP ក៏បានអនុវត្តគំនិតផ្តួចផ្តើមមួយចំនួនដែលជាដៃគូដែលរួមមាន កម្មវិធីសមុទ្រចិនខាងត្បូងរបស់ UNEP, PEMSEA, COMDEKs ដែលជាផ្នែកមួយនៃការផ្តួចផ្តើមរបស់ Satoyama និងជេដបូកនៅសហគមន៍ CBR+ ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់ UNREDD ហើយថ្មីនេះ កម្មវិធីផ្នែប្រឌិតបួនទៀត គឺកម្មវធី MAP CBA, Blue Economy កម្មវិធីទទួលបានថាមពលរបស់ជនជាតិដើមភាពតិច IPs Access to energy និងCOMDEKs phase IV និងCBA phase 3 ក៏ត្រូវបានអនុវត្តក្នុងតំណាកាល ទី 7 នេះដែរ។ គម្រោងសរុបដែលបានទទួលជំនួយខ្នាតតូចតាំងពីដំណាក់កាលចាប់ផ្តើមរហូតដល់ OP៧ មានចំនួន ២៦៩ ដែលបានផ្តល់ថវិកាសរុបជាង 9540258 ដុល្លារអាមេរិកដល់ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិង COBs និងបានទទួលសហម្ចាស់ជំនួយពីអង្គការម្ចាស់ជំនួយនានាជាសាច់ប្រាក់ចំនួន 2859629 ដុល្លារនិងសហហិរញ្ញប្បទានជារបស់/សេវាកម្ម 5469368 ដុល្លារដុល្លារអាមេរិច។

## បញ្ហាបរិស្ថានចំបងៗ

បញ្ហាបរិស្ថានដែលបាន និងកំពុងបានប្រឈមក្នុងក្របខណ្ឌសកល ដូចជាការបាត់បង់ ឬការរិចរិលប្រព័ន្ធអេកូឡូស៊ី ការបាត់បង់ជីវចម្រុះ ការបាត់បង់ព្រៃឈើ ការប្រែប្រួលអាកាសធាតុ កម្រិតនៃការកើនឡើងនៃកាបូនឌីអុកស៊ីត និងឧស្ម័នផ្ទះកញ្ចក់ផ្សេងទៀតនៅក្នុងបរិយាកាសរបស់យើង ការរិចរិលដី និងការបំពុលទឹក

និងបរិស្ថាន គឺជាចំណោតមួយដ៏ចំបង ចំពោះយើងទាំងអស់គ្នា ជាពិសេសប្រជាពលរដ្ឋក្រីក្រ ដោយសារពួកគាត់ពឹងផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិ ហើយពួកគាត់ច្រើនតែរស់នៅក្នុងប្រព័ន្ធអេកូឡូស៊ីដែលងាយខូចខាត។

## ទិសដៅជាយុទ្ធសាស្ត្រនៃការផ្តល់មូលនិធិ ( Priority themes )

អាទិភាពនឹងត្រូវផ្តល់ទៅឱ្យគម្រោងទាំងឡាយណាដែល មានបំណងធ្វើគម្រោងមួយ ឬច្រើន ដែលឆ្លើយតបទៅនឹងគំនិតផ្តួចផ្តើមនានាដូចខាងក្រោមៈ

### 1. ការអភិរក្សតាមសហគមន៍នូវប្រព័ន្ធអេកូឡូស៊ី និងប្រភេទសត្វដែលរងការគំរាមកំហែង

- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារ តាមរយៈការគាំទ្រដល់ការធ្វើនិយ័ត្តកម្ម និងរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ និងអនុវត្តផែនការគ្រប់គ្រងសហគមន៍ទាំងនោះ។
- ធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត និងវិធីសាស្ត្រ**មេត្រីភាពជីវចម្រុះ**ដែលដឹកនាំដោយសហគមន៍រួមទាំងការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍ លើកកម្ពស់ការអនុវត្តន៍កសិ-រុក្ខកម្ម កសិកម្មវៃឆ្លាតតាមអាកាសធាតុ ការដាំកូនឈើ ការប្រមូល និងកែឆ្នៃផលិតផលដែលមិនមែនឈើ (NTFPs)ប្រកបដោយនិរន្តរភាព។
- លើកកម្ពស់សកម្មភាពដែលដឹកនាំដោយសហគមន៍សម្រាប់ការពារប្រភេទសត្វដែលរងការគំរាមកំហែង ដោយផ្តល់ឱ្យនូវមធ្យោបាយ និងគោលដៅច្បាស់លាស់សម្រាប់សហគមន៍
- ប្រមូល និងប្រើប្រាស់ចំណេះដឹងដើមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើម្បីគាំទ្រដល់ការកំណត់ព្រំប្រទល់ និងបោះបង្គោលព្រំសហគមន៍ព្រៃសហគមន៍ និងការគ្រប់គ្រង
- បង្កើត និងពង្រឹងបណ្តាញជនបង្គោលក្នុងមូលដ្ឋាន ដែលអាចជួយឧទ្យានុរក្ស ក្នុងការអនុវត្តច្បាប់ និងបទបញ្ញាតិនានាក្នុងតំបន់ការពារសហគមន៍របស់សហគមន៍។
- លើកទឹកចិត្តដល់កិច្ចប្រឹងប្រែងឱ្យមានកិច្ចសហការក្នុងការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងសកម្មភាពខុសច្បាប់ ក្នុងតំបន់ការពារ រួមទាំងឧទ្យាជាតិភ្នំក្រវាញកណ្តាល និងជំរុញឱ្យមានការចូលរួមពីសហគមន៍ក្នុងកម្មវិធីធ្វើឱ្យប្រសើរឡើងវិញនូវធនធានព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី។

### 2. កសិកម្ម និងជលផលប្រកបដោយនិរន្តរភាព និងសន្តិសុខស្បៀង

- គាំទ្រការដាំដំណាំច្រើនមុខ និងការកែលម្អបច្ចេកទេសកសិកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតកម្មកសិកម្ម និងផ្សារភ្ជាប់ទៅនឹងទីផ្សារ ដែលរួមចំណែកក្នុងការបង្កើនភាពធនរបស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ។
- សម្របសម្រួលការអភិវឌ្ឍន៍ជំនួញខ្នាតតូច និងការទទួលបានឥណទានដែលមានទំនាក់ទំនងជាមួយនឹងការកែច្នៃ និងទីផ្សារផលិតផលមិនមែនឈើ (NTFPs) ដូចជាជ័រទឹក សិប្បកម្ម និងឱសថបុរាណ...។ល។

- បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃផលិតកម្មស្បៀងជាទូទៅ និងតម្លៃនៃខ្សែចង្វាក់ផលិតកម្ម រួមទាំងប្រព័ន្ធអេកូឡូស៊ីងាយរងគ្រោះ។
- បង្កើនការធ្វើពិពិធកម្ម និងការកែលម្អជីវភាពតាមរយៈការជំរុញកសិកម្មវៃឆ្លាត (Climate Smart Agriculture) កសិរុក្ខកម្ម និងធ្វើពិពិធកម្មប្រាក់ចំណូល តាមរយៈការអភិវឌ្ឍយន្តការហិរញ្ញវត្ថុប្រកបដោយចីរភាព ដូចជាការចងក្រងក្រុមសន្សំប្រាក់ / ទុនបង្វិល សហគមន៍អេកូទេសចរណ៍ សហគមន៍កសិករ និងសហគ្រាសខ្នាតតូច។
- ដកចេញនូវសកម្មភាពកាប់បំផ្លាញព្រៃឈើចេញពីខ្សែសង្វាក់ផ្គត់ផ្គង់ និងពង្រីកការដាំស្តារឡើងវិញនូវដីដែលត្រូវបានបំផ្លាញ ឬដីព្រៃរិចរិល។ ជំរុញការដាំដើមឈើ រួមទាំងព្រៃលិចទឹកនៅតំបន់ដែលមានភាពរិចរិលដែលនៅក្នុង CPAs, CF និង CFi ។

### 3. អត្ថប្រយោជន៍រួមនៃថាមពលដែលចំណាយតាបូនទាប

- គាំទ្រកិច្ចផ្តួចផ្តើមឲ្យទទួលបានថាមពលនៅថ្នាក់មូលដ្ឋាន ជាពិសេសការផ្តល់ឱ្យជនជាតិដើម រួមទាំងការធ្វើបង្ហាញ និងការសាកល្បងជម្រើសនានានៃការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជា វារីអគ្គីសនីខ្នាតតូច ថាមពលពន្លឺព្រះអាទិត្យ និងឡជីវឧស្ម័ន
- លើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពនៅមូលដ្ឋាន រួមទាំងការធ្វើបង្ហាញ និងការសាកល្បង ដូចជាចង្ក្រានសន្សំសំចៃអុស និងបច្ចេកទេសថ្មីៗដ៏ទៃទៀត
- ផ្តល់ការកសាងសមត្ថភាព ដើម្បីឲ្យសហគមន៍អាចបង្កើត និងប្រើប្រាស់បច្ចេកទេស តាមរយៈផ្តល់កញ្ចប់ថវិកាតូចៗដែលជាកាតាលីករ ឲ្យអាចបង្កើតបច្ចេកទេសថ្មីៗបាន។

### 4. សម្ព័ន្ធភាពក្នុងតំបន់ និងសកលសម្រាប់ការគ្រប់គ្រងសារធាតុគីមី និងកាកសំណល់

✓ ការគាំទ្រឱ្យមានដំណោះស្រាយថ្មីៗក្នុងតម្លៃសមស្រប និងដែលអាចអនុវត្តបានសម្រាប់ការគ្រប់គ្រងសារធាតុគីមី នៅក្នុងកិច្ចប្រឹងប្រែងរួមជាមួយដៃគូ SGP ក៏ដូចជា ដៃគូថ្មីៗផងដែរ ដែលរួមទាំង ស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានស្រាវជ្រាវ វិស័យឯកជន និងទីភ្នាក់ងារអន្តរជាតិ។ កិច្ចប្រឹងប្រែងនានានឹងមានរាប់បញ្ចូល ស្ត្រី និងជនជាតិដើមភាគតិច ដែលនៅតែពុំបានចូលរួម នៅក្នុងគ្រប់ទិដ្ឋភាពនៃការធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី និងការទុកដាក់កាកសំណល់ឲ្យបានត្រឹមត្រូវ។

✓ លើកកម្ពស់ការប្រើប្រាស់ជីគីមី និងថ្នាំគិមីកសិកម្មឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព ដែលហៅថា ទម្លាប់ល្អក្នុងកសិកម្ម (GAP) ដើម្បីកាត់បន្ថយភាពកខ្វក់បណ្តាលពីសារធាតុគីមី

✓ គាំទ្រដល់សហគមន៍ដែលស្ថិតនៅជួរមុខនៃការគំរាមកំហែងពីសារធាតុគីមី ទោះបីជាអ្នកប្រើប្រាស់ ឬ ជាអ្នកបរិភោគក៏ដោយ

✓ បង្កើនការយល់ដឹងអំពីការប្រើប្រាស់ជីគីមី និងថ្នាំគីមីកសិកម្មឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព និង គាំទ្រដល់សហគមន៍ឱ្យយល់ពីការគំរាមកំហែង/ភាពកខ្វក់បណ្តាលពីសារធាតុគីមី ដែលនឹងកែប្រែអាកប្បកិរិយាក្នុងការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងសារធាតុគីមីដទៃទៀត និង/ឬ សំណល់រឹង រាវ។

5. **វេទិកាសន្ទនា គោលនយោបាយ និងផែនការអភិវឌ្ឍន៍នានា រវាងសង្គមស៊ីវិល- រដ្ឋាភិបាល - វិស័យឯកជន**

- លើកកម្ពស់សំលេងសហគមន៍ និងគាំទ្រការចូលរួមរបស់សហគមន៍ក្នុងការរៀបចំគោលនយោបាយជាតិ និងសកលស្ដីពីការអភិវឌ្ឍន៍យុទ្ធសាស្ត្រទាក់ទងនឹងបរិស្ថានពិភពលោក និងបញ្ហាការអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- GEF SGP នឹងផ្ដល់ការគាំទ្រដល់សហគមន៍ដើម្បីចូលរួមក្នុងវេទិកាសន្ទនា គោលនយោបាយ និងផែនការអភិវឌ្ឍន៍នានា រវាងសង្គមស៊ីវិល- រដ្ឋាភិបាល - វិស័យឯកជនដែលរៀបចំឡើងដោយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា / អង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា និងគម្រោងនានារបស់UNDP។

6. **លើកកម្ពស់បរិយាប័ន្នសង្គម**

- លើកកម្ពស់គំនិតផ្ដួចផ្ដើមនេះនៅក្នុងគោលដៅ គ្រប់គម្រោងទាំងអស់ដែលទទួលជំនួយពីកម្មវិធីខ្នាតតូច ត្រូវតែបញ្ជ្រាបបរិយាប័ន្នសង្គមទៅក្នុងគម្រោងរបស់ខ្លួន។

7. **ការគ្រប់គ្រងចំណេះដឹង**

- ចងក្រងចំណេះដឹង និងមេរៀនដែលទទួលបានពីការអនុវត្តន៍គំរោង និងសកម្មភាពនានា
- បង្កើនសមត្ថភាពរបស់អង្គការសង្គមស៊ីវិល និងអង្គការសហគមន៍
- រៀបចំដឹកនាំការផ្លាស់ប្ដូរបទពិសោធន៍ ភាគខាងត្បូង-ខាងត្បូងដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យានិងការចម្លងនូវការអនុវត្តល្អៗទៅសហគមន៍ផ្សេងៗទៀតក្នុងមូលដ្ឋាន ក៏ដូចជាថ្នាក់ពិភពលោកផងដែរ។
- រាល់គំរោងដែលផ្ដល់មូលនិធិដោយ GEF SGP ចាំបាច់ត្រូវមានលទ្ធផលមួយសំរាប់ចងក្រងពីមេរៀន និងការអនុវត្តល្អដែលទទួលបានពីការអនុវត្តគម្រោងដូចជាករណីសិក្សា និងរឿងវីដេអូ/រូបថតខ្លីៗ។

**តំបន់គោលដៅ/ខេត្តគោលដៅ៖** បណ្ដាភូមិ ឃុំ ស្រុក និងខេត្តនានាដែលស្ថិតនៅក្នុង និងក្បែរឧទ្យានជាតិភ្នំក្រវាញកណ្ដាល និងនៅតំបន់នានា ដែលជីវៈចម្រុះកំពុងមានបញ្ហាធ្ងន់ធរ និងក្នុងក្នុងខេត្តដទៃទៀតដែលមានជនជាតិដើមភាគរស់នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ភាពជាដៃគូ និងកិច្ចសហការណ៍

កិច្ចសហប្រត្តិការ និងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនានានៅគ្រប់លំដាប់ថ្នាក់។ អ្នកពាក់ព័ន្ធទាំងអស់នឹងធ្វើឱ្យប្រាកដថាកម្មវិធីទាំងអស់ដែលបានទទួលការអនុម័តមានភាពងាយបត់បែនស្របតាមវប្បធម៌ និងមានលក្ខណៈសមស្រប ដែលឆ្លើយតបតាមតម្រូវការរបស់សហគមន៍នីមួយៗ រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ ក៏ដូចជាមានលក្ខណៈសមស្របខាងបច្ចេកទេស ហើយដែលកម្មវិធីទាំងនោះនឹងផ្ដល់ឥទ្ធិពលវិជ្ជមានចំពោះបរិស្ថានពិភពលោក ហើយដែលអាចធ្វើអត្តសញ្ញាណបាន។

GEF SGP ក៏នឹងធ្វើការជាមួយគម្រោងខ្នាតធំរបស់ GEF និងគំនិតផ្តួចផ្តើមថ្នាក់តំបន់ផ្សេងៗទៀតដើម្បីលើកកម្ពស់សេដ្ឋកិច្ចពណ៌ខៀវរួមមានគម្រោង UNDP / UNEP / GEF IWEco គម្រោងសមុទ្រចិនខាងត្បូងរបស់ UNEP / GEF, PEMSEA និងដៃគូដទៃទៀត។ ការអភិវឌ្ឍសមត្ថភាពការបណ្តុះបណ្តាលនិងការចងជាបណ្តាញ អាចត្រូវបានរៀបចំរួមគ្នាជាមួយនឹងគំនិតផ្តួចផ្តើមថ្នាក់តំបន់ទាំងនេះ។

## តើអ្នកណាខ្លះអាចដាក់ពាក្យស្នើសុំជំនួយ (សិទ្ធិទទួលបាន និងលក្ខណៈវិនិច្ឆ័យ)?

កម្មវិធីជំនួយខ្នាតតូច ផ្តល់ជំនួយឥតសំណងដល់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍ (LNGO/CBO) ដែលបានចុះបញ្ជីស្របច្បាប់ជាមួយក្រសួង ឬស្ថាប័នណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

- ✓ សម្រាប់អនុវត្តគម្រោង ដែលមានរយៈពេលពី ១ ឬ ២ ឆ្នាំ យោងតាមប្រភេទ/លក្ខណៈធម្មជាតិរបស់គម្រោង (វិសាលភាព ប្រភេទគម្រោង និងសមត្ថភាពរបស់អង្គការស្នើសុំជំនួយ (LNGO/CBO)។
- ✓ គម្រោងដែលបានស្នើគួរតែមានភាពច្នៃប្រឌិត ថ្មីប្រឌិត និងឈានទៅរកការផ្លាស់ប្តូរហើយមានសក្តានុពលសម្រាប់ការពង្រីក និងចម្លងទៅអនុវត្តនៅកន្លែងផ្សេងទៀត។
- ✓ គម្រោងដែលទទួលជោគជ័យគួរតែ ពិចារណាទៅលើបរិយាប័ន្នសង្គម រាប់បញ្ចូលទាំងសមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី ជនជាតិដើមភាគតិច យុវជន និងជនដែលមានពិការភាពនៅក្នុងគំនិតផ្តួចផ្តើមរបស់ពួកគេ។
- ✓ គម្រោងគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើការអភិរក្ស ការអប់រំ បច្ចេកទេស និងការងារផ្សេងៗទៀតរួមទាំងការលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ក្នុងតំបន់គោលដៅរបស់គម្រោង ប៉ុន្តែអ្នកដាក់ពាក្យស្នើសុំជំនួយគួរតែបង្ហាញឲ្យបានច្បាស់ ពីផែនការដែលអាចនាំមានឱ្យឥទ្ធិពលខ្លាំង និងលទ្ធផលច្បាស់លាស់។
- ✓ គម្រោងគួរតែនាំមកជាមួយនូវភាពជាដៃគូ និងអាចរកធនធានបន្ថែមទៀត (ឧទាហរណ៍ សហម្ចាស់ជំនួយជាមួយ INGO, គ្រឹះស្ថាន គម្រោងនានារបស់រាជរដ្ឋាភិបាល និងវិស័យឯកជនានា) ត្រូវបានផ្តល់ឱកាសឱ្យ។

## តើត្រូវដាក់ពាក្យស្នើសុំជំនួយខ្នាតតូចដូចម្តេច?

ការដាក់ពាក្យស្នើសុំជំនួយពីកម្មវិធីនេះ មានតំណាក់កាល។ ជាបឋមលោក/អ្នកត្រូវដាក់ជូននូវឯកសារសំណើរគម្រោងសង្ខេបមួយ (Project concept paper) ដែលនឹងត្រូវធ្វើការវាយតម្លៃ។ ប្រសិនបើគម្រោងសង្ខេបរបស់អ្នកទទួលបានជោគជ័យ លោក/អ្នកនឹងទទួលបានការអញ្ជើញឱ្យដាក់សំណើរគម្រោងពេញលេញ។

- ✓ សេចក្តីណែនាំអំពីរបៀបសរសេរ គម្រោងសំណើសង្ខេប មានភ្ជាប់ជូននៅទំព័របន្ទាប់។
- ✓ អ្នកដាក់គម្រោងសំណើដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចដាក់ជូនសំណើគម្រោងសង្ខេបនៅក្នុងវិស័យមួយ ឬច្រើនក្នុងចំណោមវិស័យគោល ឬសកម្មភាពជា

អាទិភាពមួយឬច្រើនក្នុងចំណោមសកម្មភាពជាអាទិភាពនានារបស់ដែលមាននៅក្នុង យុទ្ធសាស្ត្រប្រចាំប្រទេសនៃកម្មវិធីជំនួយខ្នាតតូច GEF OP7 និង CBA phase III ។

## សេចក្តីណែនាំអំពីរបៀបសរសេរគម្រោងសំណើសង្ខេប

ឯកសារគម្រោងសំណើរសង្ខេបគួរតែសរសេរឱ្យខ្លី និងច្បាស់លាស់ ដែលអាចមានពី ៥ ទៅ១០ ទំព័រ។ ឯកសារនេះអាចសរសេរដោយដៃ ឬវាយកំព្យូទ័រក៏បាន។ ឯកសារនេះត្រូវបានទទួលយកតែជាភាសាខ្មែរតែប៉ុណ្ណោះ។ ឯកសារគម្រោងសំណើរសង្ខេបនេះ ត្រូវរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

1. **ព័ត៌មានទូទៅ៖**

**ឈ្មោះគម្រោង៖**ជាធម្មតាឈ្មោះគម្រោងគួរតែឆ្លុះបញ្ចាំងពីអ្វីដែលគម្រោងរំពឹងថានឹងសម្រេចបាន

**ទីតាំងគម្រោង៖** ចំនួនភូមិ ឃុំ ស្រុក ខេត្ត ដែលជាតំបន់គោលដៅរបស់គម្រោង

**ឈ្មោះអង្គការ៖**

**អាសយដ្ឋានរបស់អង្គការ៖**

**អង្គការដៃគូប្រសិនមាន៖** សរសេរបញ្ជីឈ្មោះអង្គការដៃគូនានា ស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុនឯកជន ដែលបានជួយក្នុងការអនុវត្តគម្រោង។

**ថវិកាគម្រោងសរុប៖**

- ✓ ចំនួនថវិកាគម្រោងដែលស្នើសុំ៖
- ✓ ចំនួនថវិកាជាបដិភាគរបស់អង្គការនានា និងសហគមន៍មូលដ្ឋាន

**រយៈពេលអនុវត្តគម្រោង៖**រយៈពេលអនុវត្តអាចមានរយៈពេល ១ ទៅ ២ ឆ្នាំ អាស្រ័យទៅតាមប្រភេទគម្រោងដែលលោកអ្នកស្នើសុំ ។

**២. ការពិពណ៌នាពីគម្រោង៖**

***ក. ការថ្លែងពីបញ្ហា៖*** ពិពណ៌នាពីស្ថានភាពបច្ចុប្បន្នក្នុងសហគមន៍គោលដៅ និងបញ្ជាក់ពីបញ្ហាតម្រូវការ និងឱកាសក្នុងការដោះស្រាយ និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាទាំងនោះ។

***ខ. ពិពណ៌នាពីគោលដៅ និងគោលបំណងជាក់លាក់របស់គម្រោង៖*** (សូមពន្យល់) តើគម្រោងចង់សម្រេចបានអ្វី?

***គ. លទ្ធផលរំពឹង៖*** លទ្ធផលរយៈពេលខ្លី (outputs) លទ្ធផលរយៈពេលមធ្យម (outcomes) និងលទ្ធផលរយៈពេលវែង (impacts) លើបរិស្ថាន និងសហគមន៍។

***ឃ. សកម្មភាព៖*** កំណត់សកម្មភាពជាក់លាក់ទាំងឡាយណា ដែលគម្រោងនឹងអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក រយៈពេលខ្លី (outputs) លទ្ធផលរយៈពេលមធ្យម (outcomes) និងលទ្ធផលរយៈពេលវែង (impacts) លើបរិស្ថាន និងសហគមន៍។

***ង. វិធីសាស្ត្រអនុវត្ត និងគ្រប់គ្រងគម្រោង៖*** ធ្វើការសង្ខេបនូវរបៀបនៃការអនុវត្ត និងគ្រប់គ្រងគម្រោង។

***ច.ការវិភាគហានិភ័យ/ភាពប្រថុយប្រថានរបស់គម្រោង៖*** ធ្វើការបញ្ជាក់ពីការលំបាក ឬបញ្ហាទាំងឡាយណាដែលអាចកើតមានឡើងក្នុងពេលអនុវត្តគម្រោង និងលើកឡើងនូវសកម្មភាពដែលអង្គការអ្នកគ្រោងធ្វើ ដើម្បីទប់ទល់នឹងស្ថានភាពនោះ។

***ឆ. ភាពជាដៃគូជាមួយគម្រោងនានាក្នុងតំបន់គោលដៅ៖***ពិពណ៌នាពីរបៀបដែលគម្រោងនឹងភ្ជាប់ទំនាក់ទំនង ឬគ្រោងបញ្ចូលជាមួយគម្រោងអភិវឌ្ឍន៍នានាក្នុងសហគមន៍ដោយក្រុម និងអង្គការផ្សេងៗទៀត។

**៣.ការប៉ាន់ស្មានថវិកាសម្រាប់គម្រោង៖**សំដៅទៅលើតម្លៃសរុបនៃគម្រោងដោយគូសបញ្ជាក់ដោយចំនួនដូចខាងក្រោម៖

- ✓ **តម្លៃផ្នែករដ្ឋបាល៖** (សំដៅទៅលើខ្ទង់ថវិកាមួយចំនួនដូចជា ប្រាក់ខែបុគ្គលិកការសម្របសម្រួល ទំនាក់ទំនង និងថ្លៃធ្វើដំណើរ...។ល។ ចំនួនសរុបនៃតម្លៃរដ្ឋបាលមិនអាចលើសពី ១៥% នៃចំនួនថវិកាដែលស្នើសុំពីកម្មវិធីជំនួយខ្នាតតូចបានទេ។
- ✓ **តម្លៃផ្នែកកម្មវិធី៖** សំដៅទៅលើការប៉ាន់ស្មាន កម្មវិធីដែលអាចមានរហូតដល់ ៨៥% នៃចំនួនថវិកាដែលបានស្នើសុំពីកម្មវិធីជំនួយខ្នាតតូចសរុប
- ✓ **ចំនួនបដិភាគពីអង្គការ/ម្ចាស់ជំនួយនានា/ស្ថាប័នជាដៃគូ/សហគមន៍៖** កម្មវិធីជំនួយខ្នាតតូចនឹងផ្តល់ជំនួយឥតសំណង ចំនួន៥០% នៃចំនួនសរុបរបស់គម្រោង។ ចំណែកថវិកាចំនួន ៥០% ទៀតនឹងត្រូវផ្តល់ដោយអង្គការដែលស្នើសុំជំនួយ ឬបានមកពីការចូលរួមបដិភាគរបស់សហគមន៍ និង/ឬបានមកពីភ្នាក់ងារផ្តល់ជំនួយនានា ទោះជាក្នុងទម្រង់ជាទឹកប្រាក់ក្តី ឬជារបស់របរក្តីនិងជាសេវាកម្មផ្សេងៗក្តី។

## របៀបពិនិត្យវាយតម្លៃគម្រោងសំណើសុំជំនួយរបស់លោក អ្នក

ឯកសារគម្រោងសំណើសុំជំនួយរបស់លោក អ្នក នឹងត្រូវយកទៅពិនិត្យវាយតម្លៃ តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព ផ្តោតលើទិសដៅច្បាស់លាស់ និងតាមពេលវេលាកំណត់

## អ្នកត្រួតពិនិត្យវាយតម្លៃនឹងពិចារណាទៅលើ៖

- ✓ ទំនាក់ទំនងនៃគម្រោងសំណើរ ជាមួយនឹងយុទ្ធសាស្ត្រផ្តល់ជំនួយនៃកម្មវិធីជំនួយខ្នាតតូច GEF SGP OP7 និងCBA phase III ដែលបានជម្រាបជូនខាងលើ
- ✓ សមត្ថភាពរបស់អង្គការដែលបានដាក់ពាក្យស្នើសុំជំនួយ ក្នុងការអនុវត្តគម្រោង រួមទាំងគុណភាពនៃភាពជាដៃគូក្នុងការអនុវត្តគម្រោងផងដែរ។
- ✓ ភាពច្បាស់លាស់ និងស៊ីគ្នានៃសកម្មភាព លទ្ធផល សមិទ្ធិផល ឥទ្ធិពល និងសូចនកររបស់គម្រោង។
- ✓ ការចូលរួម និងការរួមវិភាគទានរបស់សហគមន៍។
- ✓ ការគ្រោងថវិកាបានសមស្រប។
- ✓ សង្កត់ធ្ងន់លើនិរន្តរភាពនៃការចិញ្ចឹមជីវិត និងកិច្ចការពារបរិស្ថាន។
- ✓ ការផ្លាស់ប្តូរគោលនយោបាយ ទំលាប់ និងការអនុវត្តន៍។

## ដំណើរការនៃការពិនិត្យ និងសម្រេចលើគម្រោងសំណើសង្ខេប៖

១. ឯកសារគម្រោងសំណើសង្ខេបនីមួយៗនឹងត្រូវធ្វើការជ្រើសរើសតំបូងដោយមន្ត្រីជាតិសម្របសម្រួលកម្មវិធីជំនួយខ្នាតតូច (NC) ជាមួយគណកម្មការជាតិដឹកនាំកម្មវិធីជំនួយខ្នាតតូច (NSC) ពីរទៅបីនាក់ដែលស្ម័គ្រចិត្ត រួចដាក់ជូនទៅក្នុងកិច្ចប្រជុំNSC ពេញអង្គ ដើម្បីស្នើសុំយោបល់ ពិនិត្យ និងអនុម័ត សម្រាប់ចុះវាយតម្លៃដល់ការិយាល័យ និងតំបន់គោលដៅរបស់អ្នកស្នើសុំជំនួយ។

២. ផ្អែកលើការត្រួតពិនិត្យ វាយតម្លៃនេះ មន្ត្រីជាតិសម្របសម្រួលកម្មវិធី (NC) ឬ/និងអ្នកជំនួយការ កម្មវិធី (PA) នឹងទាក់ទងដោយផ្ទាល់ទៅអ្នកដាក់សំណើ ដើម្បីផ្តល់ព័ត៌មានអំពីថា តើឯកសារគម្រោងសំណើសង្ខេបត្រូវបានបដិសេធ ឬបានទទួលការចុះវាយតម្លៃបន្តនៅការិយាល័យ និងនៅតំបន់គោលដៅរបស់អង្គការស្នើសុំជំនួយ។

៣. មន្ត្រីជាតិសម្របសម្រួលកម្មវិធី (NC) និងគណកម្មការជាតិដឹកនាំកម្មវិធី (NSC) និងចុះធ្វើការវាយតម្លៃដល់ការិយាល័យអង្គការស្នើសុំជំនួយ និងជួបជាមួយអ្នកពាក់ព័ន្ធចំបងៗ រួមទាំងសហគមន៍ និងក្រុមជនងាយរងគ្រោះផងដែរ។

៤. លទ្ធផលដែលទទួលបានពីការចុះវាយតម្លៃនៅមូលដ្ឋាន ត្រូវរាយការណ៍ជូនក្នុងកិច្ចប្រជុំពេញអង្គរបស់NSC ដើម្បីពិនិត្យ និងសម្រេចលើសំណើរគម្រោងសង្ខេបរបស់លោកអ្នក ដើម្បីផ្តល់ព័ត៌មានថាតើឯកសារគម្រោងសំណើសង្ខេប ត្រូវបានបដិសេធ ឬបានទទួលអនុសាសន៍ដើម្បីឱ្យបន្តរៀបចំគម្រោងសំណើរពេញលេញ។

៥. មន្ត្រីជាតិសម្របសម្រួលកម្មវិធីអាចជួយផ្តល់ការណែនាំ ក្នុងការរៀបចំគម្រោងសំណើរពេញលេញ

៦. គម្រោងសំណើពេញលេញរបស់លោកអ្នក នឹងត្រូវបានពិនិត្យ និងវាយតម្លៃដោយកិច្ចប្រជុំពេញអង្គរបស់គណកម្មការជាតិដឹកនាំកម្មវិធីជំនួយខ្នាតតូច។

៧. ក្រោយពីបានទទួលការសម្រេចពី NSC លើគម្រោងសំណើរពេញលេញហើយ តំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ជាមួយនឹងភាគីស្នើសុំជំនួយដោយរួមបញ្ចូលនូវដំណើរការដែលត្រូវប្រតិបត្តិ និងបែបបទរដ្ឋបាល ហិរញ្ញវត្ថុ និងពេលវេលានៃការអនុវត្តគម្រោង។

## គន្លឹះសម្រាប់អ្នករៀបចំគម្រោងសំណើ

- កំណត់ឫសគល់នៃបញ្ហា និងលំដាប់លុះដោយ នៃសកម្មភាព និងធនធានដែលត្រូវការ ដើម្បីលុបបំបាត់ កាត់បន្ថយឧបសគ្គ ឬ/និងឫសគល់នៃបញ្ហា
- កំណត់ផលប្រយោជន៍នៃគម្រោង ដែលជួយដោះស្រាយបញ្ហាបរិស្ថានជាសកល និងនៅមូលដ្ឋាន ដូចជាការបាត់បង់ជីវចម្រុះ ការប្រែប្រួលអាកាសធាតុ កិច្ចការពារដែលទឹកអន្តរជាតិការគ្រប់គ្រងសារធាតុគីមីនិងកាកសំណល់ និងការរិចរិលគុណភាពដី។
- ផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពដែលកំពុងអនុវត្តន៍ និងក្នុងករណីចាំបាច់ ត្រូវបញ្ជាក់ពីការរកចរិកាបដិភាគឱ្យបានគ្រប់គ្រាន់ ដើម្បីប្រមូល/ពង្រឹងទិន្នន័យគោល/ស្ថានភាពគោល នៅកន្លែងណាដែលចាំបាច់។
- បង្កើតការទាក់ទងផ្ទាល់រវាងគម្រោងរបស់អ្នកទៅនឹង សកម្មភាពជាអាទិភាពភាពនានា ដែលមាននៅក្នុងយុទ្ធសាស្រ្តប្រចាំប្រទេសនៃ GEF SGP OP7 និង CBA phase III។
- បង្កើតការប្រាស្រ័យទាក់ទង និងយុទ្ធសាស្រ្តផ្សព្វផ្សាយរបស់គម្រោងឲ្យបានច្បាស់។
- រួមបញ្ចូលលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោង។
- ធ្វើឱ្យប្រាកដថាមានការចូលរួមពេញលេញពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ។
- កំណត់ពេលវេលាសមស្រប (ជាធម្មតារយៈពេលសម្រាប់អនុវត្តគម្រោង មាន ១ ឆ្នាំ ទៅ ២ ឆ្នាំ អាស្រ័យទៅតាមប្រភេទ វិសាលភាពរបស់គម្រោង និងសមត្ថភាពរបស់អង្គការ)។
- ក្នុងករណីចាំបាច់ ត្រូវចងក្រងជាឯកសារ និងធ្វើការអះអាងតាមវិទ្យាសាស្រ្ត។
- ចំពោះគម្រោងដែលបង្ហាញ ឬសាកល្បងពីបច្ចេកទេសណាមួយ ត្រូវបង្ហាញពីផែនការថាតើសកម្មភាពនៃគម្រោងនេះនឹងនាំឲ្យមានការផ្លាស់ប្តូរបែបណាអំពីស្ថានភាពទីផ្សារសម្រាប់បច្ចេកទេសនោះ។


**សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង៖**

លោកស្រី **ងិន ណាវីរៈ** មន្ត្រីជាតិសម្របសម្រួលកម្មវិធីជំនួយខ្នាតតូច GEF SGP UNDP

នៅភ្នំពេញសិនធ័រ ជាន់ទី ៦ អគារ អេ កែងផ្លូវសុធារស និងមហាវិថីព្រះសីហនុ

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ៖ ៨៥៥ ២៣ ៨៦០ ៩១២

ទូរស័ព្ទដៃលេខ និងតេឡេក្រាម៖ ៨៥៥ ១២ ៨៤៤ ០៨៣

អ៊ីម៉ែល៖ ngin.navirak@undp.org

**Skype: Navirak Ngin**

**គេហ៍ទំព័រ:** www.sgp.undp.org